ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Oct-2012, 14:27
CMS/CFO: Uch Arun

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១២

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បណ្តឹងសារទុក្ខប្រឆាំងនឹងការបដិសេធតាមការសន្មតនៃសំណើសុំឲ្យមានចំណាត់ការ
ជាបន្ទាន់អនុលោមតាមវិធាន៣៥**

---

<u>ដាក់ដោយ</u>៖

**ក្រុមមេធាវីការពារក្តី នួន ជា**
Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW
Joshua ROSESWEIG
Sofie HOGESTOL
Renee DE GEUS

**<u>ផ្ញើជូន</u>៖**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា**
**លោកស្រី ជា លាង**
**លោក Andrew CAYLEY**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
**PICH Ang**
**Elisabeth SIMONNEAU-FORT**

១. អនុលោមតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“វិធានផ្ទៃក្នុង”) មេធាវីការពារក្តីជនជាប់ចោទ នួន ជា (“មេធាវីការពារក្តី”) តទៅនេះសូមដាក់បណ្តឹងសារទុក្ខប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់អង្គជំនុំជម្រះសាលាដំបូងនៃសំណើរបស់ខ្លួន សុំឲ្យមានចំណាត់ការជាបន្ទាន់ ជាការឆ្លើយតបទៅនឹងការលាឈប់ពីមុខតំណែងរបស់សហចៅក្រមស៊ើបអង្កេត Laurent Kasper-Ansermant (“សំណើ”)[1]។ សំណើបានដាក់ភ្ជាប់ជាមួយបណ្តឹងសារទុក្ខនេះជាឧបសម្ព័ន្ធ **ក** ។

២. សំណើនេះត្រូវបានដាក់នៅអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ ដែលមានរយៈពេលជិតប្រាំខែកន្លងមកហើយ។ មេធាវីការពារក្តីបានទំនាក់ទំនងអង្គជំនុំជម្រះសាលាដំបូងដោយបានស្វែងរកក្រៅផ្លូវការអំពីបច្ចុប្បន្នភាពទាក់ទងនឹងស្ថានភាពរបស់សំណើ តែវាហាក់ដូចជាពុំមានការសម្រេចទៅលើនេះសោះ។

៣. អង្គបុរេជំនុំជម្រះ បានទទួលស្គាល់កាលពីលើកមុនថាការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីសម្រេចលើញត្តិមួយនៅចំពោះមុខខ្លួនក្នុងពេលវេលាសមស្រប គឺជាទឡ្ហីករណ៍សម្រាប់ការប្តឹងឧទ្ធរណ៍ដោយផ្អែកលើទ្រឹស្តីនៃការបដិសេធតាមការសន្មតនៅក្នុងករណីដែល ការពន្យារពេលបែបនេះ ធ្វើឲ្យជនជាប់ចោទមិនអាចទទួលបានផលប្រយោជន៍ដែលគាត់ស្វែងរក[2]។

៤. ការពន្យាពេលនៅក្នុងករណីនេះបំពេញបានបទដ្ឋាននេះ។ សំណើនេះបង្ហាញមូលហេតុច្បាស់ដើម្បីជឿជាក់យ៉ាងច្បាស់ថាការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាលនៅក្នុងករណី០០២ កំពុងតែបន្ត ហើយចាំបាច់ឲ្យមានការស៊ើបសួរ ដើម្បីបំភ្លឺឲ្យច្បាស់ពីចរិតលក្ខណៈ និងកម្រិតនៃការជ្រៀតជ្រែកនេះ។ សវនាការនៅក្នុងករណី០០២នេះបានប្រព្រឹត្តទៅអស់រយៈពេល៦ខែ សវនាការមាន៥០ថ្ងៃ ហើយបានស្តាប់សក្ខីកម្មសាក្សីជាង២០នាក់ ហើយដែលអាចនិយាយបានថាការជំនុំជម្រះមកទល់នឹងពេលនេះ គ្របដណ្តប់

[1] ឯកសារ E-189 “សំណើសុំឲ្យមានចំណាច់ការជាបន្ទាន់អនុលោមតាមវិធាន ៣៥” ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ERN 00803004-00803019 (សំណើ)។

[2] ឯកសារ A-189/1/8 “សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ទាក់ទងនឹងការតែងតាំងអ្នកជំនាញខាងចិត្ត សាស្ត្រ” ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ERN 00233433-00233443, នៅកថាខណ្ឌ២៣-២៤ ។

បានមួយភាគបីនៃការជំនុំជម្រះនៅក្នុងករណី០០២/០១ តែនៅពុំមានការស៊ើបសួរដដែល។ លទ្ធភាពរបស់មេធាវីការពារក្តីក្នុងការតវ៉ាភាពអាចទុកចិត្តបានរបស់ភស្តុតាងដែលបានបង្ហាញនៅសវនាការត្រូវបានដាក់កម្រិតយ៉ាងខ្លាំង ហើយគោលបំណងនៃការដាក់សំណើត្រូវបរាជ័យ។ អាស្រ័យហេតុនេះ ការខកខានមិនចេញសេចក្តីសម្រេច បង្កើតបានជាការបដិសេធលើសំណើដែលបានស្នើឡើង។

៥. ការខកខានមិនចាត់ចំណាត់ការជាបន្ទាន់ គឺជាក្តីបារម្ភយ៉ាងសំខាន់ បើពិនិត្យទៅលើលក្ខណៈនៃការចោទប្រកាន់ក្នុងសំណើនេះ។ ដោយមានភស្តុតាងគាំទ្រគ្រប់គ្រាន់ សំណើនេះបានអះអាងថាឯករាជ្យភាពរបស់តុលាការ គឺមិនមានទេនៅក្នុងប្រទេសកម្ពុជា និងថាចៅក្រមកម្ពុជានៅ អវតក រួមជាមួយបុគ្គលិកជាតិដទៃទៀត មិនអាចបំពេញការងាររបស់ពួកគេឲ្យផ្ទុយទៅនឹងការចង់បានរបស់រដ្ឋាភិបាលឡើយ។ ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការដោះស្រាយការចោទប្រកាន់ដែលចំៗត្រឹមត្រូវតាមច្បាប់ទាំងនេះ ក្នុងរយៈពេល៦ខែពេញ រឹតតែបង្កើនឲ្យមានការសង្ស័យបន្ថែមដែលបានធ្វើឲ្យសំណើនេះក្លាយជាបញ្ហាសំខាន់ទី១ដែលត្រូវដោះស្រាយ។ ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល ឬយ៉ាងហោចណាស់ចៅក្រមអន្តរជាតិរបស់អង្គជំនុំជម្រះនេះ ត្រូវតែប្រកាសពីយុត្តាធិការលើបណ្តឹងសាទុក្ខនេះ ដើម្បីធានាថាការចោទប្រកាន់ក្នុងសំណើនេះត្រូវបានដោះស្រាយភ្លាមៗ។

៦. ជាងនេះទៅទៀតការលើកឡើងក្នុងបណ្តឹងនេះ បើកផ្លូវឲ្យមានបណ្តឹងសាទុក្ខភ្លាមៗ អនុលោមតាមវិធាន១០៤(ឃ) ដែលចែងពីការការប្តឹងសាទុក្ខភ្លាមៗប្រឆាំងទៅនឹងសេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ តាមវិធាន៣៥(៦)។ ការបដិសេធសំណើខាងលើតាមការសន្មត ដោយគ្មានហេតុផលត្រឹមត្រូវ គឺជាកំហុសអង្គច្បាប់ និងជាការរំលោភឆន្ទានុសិទ្ធិ តាមវិធាន១០៤(១) នៃវិធានផ្ទៃក្នុង។

៧. មេធាវីការពារក្តីសូមស្នើដោយគោរពឲ្យអង្គជំនុំជម្រះតុលាការកំពូលទទួលយកបណ្តឹងសាទុក្ខ និងផ្តល់នូវដំណោះស្រាយដែលបានលើកឡើងក្នុងសំណើដែលបានភ្ជាប់មកជាមួយនេះ។

**សហមេធាវីការពារក្តីលោក នួន ជា**

Michiel PESTMAN Andrew IANUZZI Jasper PAUW